# សេចក្តីប្រកាសព័ត៌មាន

## ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលនឹងប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៦ ខណៈសេរីភាពសារព័ត៌មាននៅកម្ពុជានៅតែមានបញ្ហាប្រឈមជាច្រើន

**ភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦** — ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ជាង១០ស្ថាប័ន នឹងរៀបចំសន្និសីទជាតិរយៈពេលពេញមួយថ្ងៃ ដើម្បីប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៦ (ថ្ងៃទី៣ ឧសភា) ដែលមានអ្នកចូលរួមប្រមាណ ១៥០នាក់ រួមមាន អ្នកសារព័ត៌មាន អ្នកបម្រើការក្នុងវិស័យសារព័ត៌មាន អ្នកបង្កើតមាតិកា អ្នកសារព័ត៌មានពលរដ្ឋ តួអង្គសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អ្នកតស៊ូមតិសម្រាប់សិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយ យុវជន ស្ថានទូតបរទេសប្រចាំកម្ពុជា និងស្ថាប័នរដ្ឋាភិបាល។

សន្និសីទនេះនឹងប្រារព្ធឡើងក្រោមប្រធានបទ «**ការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយសេរី និងមានទំនួលខុសត្រូវដើម្បីសន្តិភាព និងការអភិវឌ្ឍ**» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី**៣០ ខែមេសា ឆ្នាំ២០២៦** នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងរាជធានីភ្នំពេញ។ សន្និសីទនេះមានគោលបំណងបញ្ជាក់ជាថ្មីនូវគោលការណ៍ជាមូលដ្ឋាននៃសេរីភាពក្នុងការបញ្ចេញមតិ និងដើម្បីទទួលស្គាល់តួនាទីដ៏សំខាន់នៃប្រព័ន្ធផ្សព្វផ្សាយសេរី ឯករាជ្យ និងចម្រុះ ក្នុងការជំរុញសិទ្ធិមនុស្ស លើកកម្ពស់អភិបាលកិច្ចល្អ និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាព។

នៅក្នុងគំនិតផ្តួចផ្តើមរួមគ្នាពីបណ្តាស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ក្រុមអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ សន្និសីទនេះក៏មានគោលបំណងលើកកម្ពស់ការសន្ទនាប្រកបដោយបរិយាបន្ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់មូលដ្ឋាន។ ការពិភាក្សាទាំងនេះរំពឹងថា នឹងជំរុញការយល់ដឹងកាន់តែប្រសើរ បង្កើនកិច្ចសហប្រតិបត្តិការ និងបង្កើតអនុសាសន៍ ជាក់ស្តែងដើម្បីពង្រឹងការការពារអ្នកសារព័ត៌មាន និងគាំទ្រដល់បរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈអំណោយផលជាងមុន។

សន្និសីទនេះនឹងមានកិច្ចពិភាក្សាសំខាន់ៗចំនួនបី រួមមាន៖ ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ ការរាយការណ៍ព័ត៌មាន អំឡុងពេលមានវិបត្តិ និងតួនាទីរបស់បញ្ញាសិប្បនិម្មិតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។ សន្និសីទនេះក៏នឹងរួមបញ្ចូលនូវការបង្ហាញរបាយការណ៍សិក្សាថ្មីមួយស្តីពី សារព័ត៌មានបរិស្ថាននៅកម្ពុជា ដែលបង្ហាញអំពីបញ្ហាប្រឈមរបស់ អ្នកសារព័ត៌មានបរិស្ថាននៅកម្ពុជា និងតម្រូវការគាំទ្រនានារបស់ពួកគេ។ ក្រៅពីនេះសន្និសទីក៏នឹងបង្ហាញពីការវិភាគស្តីពីក្តីកង្វល់ និងអនុសាសន៍សំខាន់ៗ ដែលកើតចេញពីការវិភាគផ្នែកច្បាប់របស់ក្រុមអង្គការសង្គមស៊ីវិលទៅលើខ្លឹមសារនៃប្រកាស ស្តីពីលក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន ព្រមទាំងរបាយការណ៍ស្តីពីសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក២០២៦ របស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ដែលលើតំបន់អាស៊ី ប៉ាស៊ីហ្វិច។ កិច្ចពិភាក្សាទាំងនេះនឹងនាំយកអ្នកសារព័ត៌មាន អ្នកជំនាញផ្នែកច្បាប់ អ្នកបង្កើតគោលនយោបាយ អ្នកសិក្សា ស្រាវជ្រាវ និងមន្ត្រីរដ្ឋាភិបាល ដើម្បីចែករំលែកទស្សនៈ និងបទពិសោធន៍ជាក់ស្តែង៕

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក **ណុប វី** នាយកប្រតិបត្តិ សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

ed@camboja.net

លោក **សន សារ៉ាត** អ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ និងតស៊ូមតិ នៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

sarath.sorn@camboja.net